

# នាដការីព្រហ្មចារីស្លៀកសពាក់ស

# រាំបួងសួងបារមីកក្រើកអង្គរ

## * មានអព្ភូតហេតុចម្លែកព្រឺក្បាលគ្រប់គ្នា



អ្នកស្រី ឌីណាវីត ពេលផ្តល់បទសម្ភាសន៍

ពិធីរាំតាំបុរាណយ៉ាងចម្លែក ថ្វាយព្រះពរក្នុងពេលចម្រើនព្រះជន្មព្រះករុណា ព្រះមហាក្សត្រព្រះបាទនរោត្តមសីហមុនី កាលពីក្នុងខែឧសភាកន្លងទៅនេះ នៅមុខប្រាង្គប្រាសាទអង្គរវត្ត បានជួបហេតុអស្ចារ្យនោះ គឺសម្លេងប៉ូវយ៉ាងកងរំពងនៃពពួកបក្សីរបៀង នៅពេលដែលក្រុមរាំបញ្ចប់បទបួងសួងដល់អស់បារមីក្នុងតំបន់អង្គរឱ្យមកប្រទ្រង់ទឹកដីកម្ពុជាដ៏ពិសិដ្ឋនៃយើង ហើយបន្ទាប់មកទៀតថ្ងៃបើថ្ងៃមេឃខ្មៅងងឹតនៅពេលរាំបញ្ចប់ធម្មជាតិបានផ្តល់ឱកាសគ្រប់គ្រាន់ក្នុងកិច្ចការពិធី ។ ចប់ពិធីភ្លាមគ្រាន់តែរៀបចំដាក់ជើងដើរចេញមិនទាន់ទាំងចេញបំណើរផង ព្រះពិរុណបានបង្អុរយ៉ាងខ្លាំងធ្លាក់ចុះលាយឡំជាមួយផ្គរលាន់ ថ្ងៃមេឃស្រាយស្ងប់យាយពពកខ្មៅងងឹតសូមធម្មឱ្យព្រឺព្រួចបំផុត ។

●●●លោកស្រី ក្លោរីន ឌីតាវីត នាយកមូលនិធិ ឌីតាវីត សំរាប់កម្ពុជា ដែលបានរៀបចំរាំថ្វាយព្រះពរនេះ បានមានប្រសាសន៍ថា ភាពអស្ចារ្យ និងអព្ភូតហេតុដែលបានបន្តាញឲ្យឃើញពិតៗចំពោះមុខអ្នករាំគ្នានៅឱកាសនេះ គឺមានពពួកបក្សីស្រែករពេចអបអរទើបតែក្រោយបួងសួងគង់រាំងឡើង ធ្វើឲ្យយើងព្រឺក្បាលគ្រប់គ្នានៅកណ្តាលស្មៀរាត្រីនឹមនោះឡើយ ។ ក្រោយការបួងសួងចប់ភ្លាម មេឃពព្រុះដោយពពកខ្មៅងងឹត បានបង្អុរភ្លៀងយ៉ាងធំដោយមានផ្គររន្ទះខ្លាំងបាក់ពណ្ណក់ថា បារមីនៃអ្នកព្រះពីដ៏ខ្មែរដែលធ្លាប់ខ្វាំងស្ថានមកសណ្ឋិតក្នុងវិស្ថានសក្ការៈនៅតាមប្រាសាទទាំងអស់នេះវិញ ។ ក្លួនមំាដក្រោយភាពមនោះឡើយ ភ្លៀងនិងផ្គរផ្ទាយក៏ឈប់សចេញពេញផ្ទៃមេឃស្រឡះដែលមើលទៅគួរឲ្យជាប់ចិត្តក្រៃលែង ។

ក្រុមរាំមួយនេះមានភាពចម្លែក ព្រមទាំងការតុបតែងរបស់នាដការីទាំងអស់គឺមិនស្លៀកសពាក់ស ដែលជាគ្រឿងតុបតែងរបស់ក្រុមរាំព្រហ្មចារីនោះ ។ ទាក់ទងនឹងការរាំចម្លែកនេះ លោកស្រី ក្លោរីន ឌីតាវីត ក្លោរ







បុណ្យចំរើនព្រះជន្មនេះ គឺខ្ញុំបានសិក្សាជាមួយនឹងលោកសាស្ត្រាចារ្យ ឡឿង សៀង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសម្តេចព្រះរាម នរោត្តម បុប្ផាទេវី ដែលទ្រង់ជំនាញវិជ្ជាការរាំបុរាណជួយផ្តល់យោបល់ ហើយដោយសារខ្ញុំគិតថា ការថ្វាយព្រះពរព្រះករុណាតាមវិធីខ្មែរទស្សន៍ ឬការដែលគេមិនអាចដាស់អស់ព្រលឹងបារមីឲ្យមកថែរក្សា និងបកសញ្ជឹកគ្រាប់ទឹកដី និងរក្សាព្រះមហាក្សត្រយើងនោះ ខ្ញុំក៏ចាត់តាំងពិធីនេះឡើង ។ លោកស្រី ឌិន ការីត មានប្រសាសន៍ថា នាដការីទាំងអស់មានចំនួន២៤នាក់ ដែលក្នុងពេលនោះគេជ្រើសមួយទៅរាំជាមួយគ្នាថ្វាយព្រះករុណាព្រះមហាក្សត្រ ហើយការតុបតែង គឺស្លៀកសម្លៀកបំពាក់សក្បួស និងមានការរចនាម៉ូដសក់តាមការសិក្សាចេញពីចម្លាក់នៅលើជញ្ជាំងប្រាសាទអង្គរធំនេះ ។ ការរាំនៅប្រាសាទបន្ទាយស្រីវិញ គឺមាននាដការី៨នាក់ស្មើនឹងព្រះជន្មព្រះមហាក្សត្រយើង ។ ចំណែកគ្រឿងសក្ការៈបូជា គឺប្រើបែបបុរាណសុទ្ធមានបាយសី និងជើងការពានលើ ឬស្លាធំ និងមានស្លាប់ម្លូ ហើយជារបស់ខ្មែរសុទ្ធសាធ និងមានរៀបចាស់ទុំ១១ថ្នាក់ផង ។ លោកស្រី គន្ធាវីរីឌ ឌិនការីត ពន្យល់ថា នាដការីគឺជាស្រីព្រហ្មចារីយ៍បរិសុទ្ធ ចំណែកការស្លៀកស គឺបង្ហាញពីភាពបរិសុទ្ធដ៏ថ្លាថ្លាគ្មានមន្ទិលសៅហ្មងឡើយ ។ ចំណែកការរចនាម៉ូដសក់វិញ គឺយកលំនាំតាមចម្លាក់ក្នុងវិមានសក្ការៈនៃប្រាសាទអង្គរនេះដែរ ។ ចំពោះពេលវេលា គឺយកម៉ោងគម្ពុជ្រប៉ះ ដែលគ្មានអ្នកទស្សនាចេញចូលរំខាន គ្មានភ្លើងអគ្គិសនីបំភ្លឺ គឺប្រើភ្លើងទៀន និងមិនតុបតែងដោយគ្រឿងកែកំប៉ោងនានា និងចម្លាក់តាមជញ្ជាំង និងប្រាង្គប្រាសាទយកធ្វើជាកំណត់ឡើយ ។ ការរៀបចំបែបនេះ គឺធ្វើចំពោះព្រះអង្គនៃព្រះបារមីរក្សាប្រទេសកម្ពុជាជិតពីរពាន់ឆ្នាំ ហើយដែលជាការយាងដាស់គ្រប់បារមីទាំងអស់នៅទីនេះឲ្យមកសញ្ជឹកឡើងវិញតាមរបៀបរបស់ និងបួងសួងដែលសម្តែងដោយក្រមុំដែលមានភាពបរិសុទ្ធគ្មានសៅហ្មង ។

លោកស្រី គន្ធាវីរីឌ ឌិនការីត គូរលឺថា មូលនិធិឌិនការីត សំរាប់កម្ពុជា បង្កើតឡើងតាំងពីឆ្នាំ១៩៩៩ ដោយធ្វើការលើកម្មវិធីជាច្រើន មានអប់រំ កសិកម្ម សុខភាពអនាម័យ ប្រជាជនបរិត្យាគ្រួសារ ជួញដូរមនុស្ស... ដើម្បីជួយផលប្រយោជន៍ដល់ប្រជាជន២៥០០គ្រួសារនៅក្នុង១៩ភូមិ នៃស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ អំពីមូលហេតុដែលនាំឲ្យកើតសាលាសិល្បៈរាំនេះឡើង គឺក្រោយពីព្រះករុណាសម្តេចឪព្រះនរោត្តម សីហនុ ទ្រង់ប្រទានរឿងកូនមួយរឿងដល់កូនចៅទស្សនា ហើយដោយឃើញថាកូននោះមានឥទ្ធិពលលើមនុស្សទៅលើពលរដ្ឋច្រើន ខ្ញុំបានអញ្ជើញគ្រូបារាំងជនជាតិលោកតា គង់ ណៃ មកច្រៀងរឿងអប់រំអនាម័យការសំអាតក្នុងភូមិដ្ឋានថែម ។ ស្របពេលនោះក៏មានសិល្បករម្នាក់មកពីអាមេរិក គឺប្អូនប្រុស ប្រាជ្ញ ឈើ ដែលជំនាញចម្លាក់រាំបាទាំងជាយសម្បុទ្ធជួយសម្តែងផង បានដាស់ស្មារតីកូនអ្នកស្រុកតំបន់នោះចង់ឲ្យខ្ញុំបើកសាលាបង្ហាត់សិល្បៈនេះឡើង ។ សាលានេះមានអាយុតែជាង២ឆ្នាំទេ ហើយមានកុមារា កុមារី១៥៦នាក់ចូលរួមក្រោមការបើកបាត់ពីគ្រូសិល្បៈរបស់ខេត្ត និងមានការគ្រួតពិនិត្យពីសម្តេចព្រះរាម នរោត្តម បុប្ផាទេវី និងលោកគ្រូ ឡឿង សៀង ។

ថា ខ្ញុំជាកូនអ្នកស្រុកដ៏នៅខ្មែរមួយរូបដែលបានចាកចេញពីមាតុប្រទេសតាំងពីឆ្នាំ១៩៧០ ពេលដែលកើតរដ្ឋប្រហារទម្លាក់សម្តេចឪ ។ មុនចាកចេញពីមាតុប្រទេស ខ្ញុំបានបញ្ចប់ការសិក្សានៅសាលាបារាំងរង ភ្នំពេញ ក្នុងអាយុ១៨ឆ្នាំ និងរៀននៅមហាវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកវិទ្យាសាស្ត្រសង្គម ។ លោកស្រីបន្តថា ខ្ញុំបានចេញទៅអង់គ្លេសជាមួយនឹងប្តី និងបងប្អូនទាំង៥នាក់ ហើយកសាងគ្រួសារជាមួយជនជាតិអង់គ្លេសនៅទីនោះរហូត







មក ។ ខ្ញុំនៅតែនឹករលឹកមាតុភូមិខ្មែរជានិច្ច ព្រោះខ្ញុំចង់ចូលការសេរភាពជាតិអស់ហើយក៏ដោយ ។ ដល់ឆ្នាំ១៩៩០ ពេលដែលប្រទេសជាតិមានការបង្រួបបង្រួម ខ្ញុំក៏វិលមកមាតុភូមិ ហើយដោយឃើញប្រជាពលរដ្ឋយើងជួបការលំបាកក្រខ្វះខាត់ ក៏កើតគំនិតចង់ជួយ ។